ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការគ្រប់គ្រងលើការវាស់វែងនិងការផលិតផែនទី និងលើអាជីវកម្មវាស់វែងនិងការផលិតផែនទី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្មឆ្នាំ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី១៥ ខែ... ឆ្នាំ២០១៦

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងគ្រប់គ្រងលើការវាស់វែងនិងការផលិតផែនទី និងលើអាជីវកម្មវាស់វែងនិងផលិតផែនទីនៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅដូចតទៅ៖

- ពង្រឹងនិងធ្វើឱ្យទំនើបនូវប្រព័ន្ធវាស់វែងនិងការផលិតផែនទី
- កំណត់នូវស្តង់ដានិងសមត្ថកិច្ចក្នុងការវាស់វែងនិងផលិតផែនទី ដើម្បីធានាភាពជាក់លាក់ និងលទ្ធផលការងារមិនជាន់គ្នា
- លើកទឹកចិត្តដល់ការចូលរួមរបស់វិស័យឯកជនលើការងារវាស់វែងនិងការផលិតផែនទី
- ទប់ស្កាត់ការផ្សព្វផ្សាយ ការប្រើប្រាស់ជាសាធារណៈនូវផែនទីនិងទិន្នន័យវាស់វែង ដែលមិនត្រឹមត្រូវនិងគ្មានការអនុញ្ញាត។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះបុគ្គលដែលធ្វើសកម្មភាពវាស់វែង ផលិតផែនទី និងប្រកបអាជីវកម្មផ្តល់សេវាវាស់វែងនិងផលិតផែនទីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤.-**

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើនៅក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចបានកំណត់ក្នុងសទ្ទានុក្រមជាឧបសម្ព័ន្ធ។

## ជំពូកទី២

## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៥.-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានសមត្ថកិច្ចទទួលស្គាល់សមត្ថភាពវាស់វែងរបស់អ្នកវាស់វែងនិងក្រុមហ៊ុនវាស់វែង តាមដាននិងត្រួតពិនិត្យការអនុវត្តរបស់អ្នកវាស់វែង ការធ្វើអាជីវកម្មវាស់វែងនិងការផលិតផែនទីរបស់ក្រុមហ៊ុនវាស់វែង។

ការវាស់វែងគោល និងការផលិតផែនទីគោលជាសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ក្នុងករណីចាំបាច់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុនវាស់វែងនានា ដើម្បីធ្វើការវាស់វែងគោលនិងការផលិតផែនទីគោល។

ការវាស់វែងទូទៅឬការផលិតផែនទីជំនាញ អាចត្រូវអនុវត្តដោយក្រសួង ស្ថាប័ន ក្រុមហ៊ុនវាស់វែង ឬអ្នកវាស់វែងដែលបម្រើការនៅក្រុមហ៊ុនណាមួយ។

ការវាស់វែងព្រំប្រទល់ប្រទេស ជាសមត្ថកិច្ចរបស់អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន។ ការប្រើប្រាស់ទិន្នន័យព្រំប្រទល់ប្រទេស សម្រាប់ការវាស់វែងនិងផលិតផែនទីរបស់ព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្តតាមការណែនាំរបស់អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន និងត្រូវស្របទៅតាមស្តង់ដាដែលបានកំណត់ក្នុងមាត្រា៨នៃអនុក្រឹត្យនេះ។ រាល់ការផលិតផែនទីដែលពាក់ព័ន្ធនឹងខ្សែបន្ទាត់ព្រំប្រទល់ប្រទេស ដែលអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែនពុំទាន់បានកំណត់ជាកំលាក់នៅឡើយ អ្នកផលិតត្រូវសរសេរក្នុងផែនទីនោះថា "ខ្សែបន្ទាត់ព្រំដែននៃផែនទីនេះពុំមានតម្លៃផ្លូវការជាអន្តរជាតិឡើយ"។ ការផលិតផែនទីឋានលេខាសម្រាប់បម្រើដល់វិស័យយោធា ជាសមត្ថកិច្ចរបស់នាយកដ្ឋានភូមិសាស្ត្រនៃក្រសួងការពារជាតិ និងត្រូវផ្អែកលើទិន្នន័យវាស់វែងគោល។

**មាត្រា៦ .-**

ការវាស់វែងនិងការផលិតផែនទីនៅព្រះរាជាណាចក្រកម្ពុជាអាចត្រូវធ្វើឡើងដោយអ្នកវាស់វែងមានវិញ្ញាបនបត្រវាស់វែង ដែលជាមន្ត្រីកំពុងបម្រើការក្នុងស្ថាប័នរដ្ឋណាមួយឬជាអ្នកធ្វើការក្នុងក្រុមហ៊ុនមានអាជ្ញាបណ្ណវាស់វែង ស្របតាមស្មារតីនៃអនុក្រឹត្យនេះ ឬធ្វើការក្នុងក្រុមហ៊ុនផ្សេងទៀតដែលចុះបញ្ជីនៅក្រសួងមានសមត្ថកិច្ច។

## ជំពូកទី៣

## ស្តង់ដាក្នុងការវាស់វែងនិងការផលិតផែនទី

**មាត្រា៧ .-**

រាល់ការផលិតផែនទីជំនាញគ្រប់ប្រភេទ អ្នកផលិតត្រូវសហការនិងប្រើប្រាស់ទិន្នន័យផែនទីគោលរបស់អគ្គនាយកដ្ឋានសុរិយោដីនិងភូមិសាស្ត្រនៃក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ហើយត្រូវផ្តល់នូវផែនទីដែលបានផលិតរួចចំនួន២(ពីរ)ច្បាប់ ជូនអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ និងចំនួន១(មួយ)ច្បាប់ ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ក្នុងករណីដែលផែនទីនោះមានបង្ហាញអំពីព្រំប្រទល់ប្រទេស ដើម្បីតម្កល់ទុកជាឯកសារ លើកលែងតែផែនទីពាក់ព័ន្ធនឹងការការពារជាតិ។ រាល់ការបោះពុម្ពផែនទីកម្ពុជាគ្រប់ប្រភេទទាំងនៅក្នុងនិងក្រៅប្រទេសសម្រាប់ធ្វើអាជីវកម្ម ត្រូវមានការអនុញ្ញាតនិងចុះទិដ្ឋាការពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ជាមុន។

**មាត្រា៨ .-**

ការវាស់វែងគោលនិងការវាស់វែងទូទៅ ត្រូវអនុវត្តតាមស្តង់ដាដូចខាងក្រោម៖

១- ទីតាំងរបស់ចំណុចនីមួយៗត្រូវតាងនៅក្នុងនិយាមកាភូមិសាស្ត្រនិងកម្ពស់ធៀបទៅនឹងកម្ពស់មធ្យមនៃទឹកសមុទ្រ។ ប្រសិនបើចាំបាច់ ទីតាំងរបស់ចំណុចនីមួយៗអាចត្រូវតាងក្នុងនិយាមកាចតុរង្គឬនិយាមកាមុំ

២- ចម្ងាយនិងផ្ទៃក្រឡាត្រូវតាងនៅក្នុងតម្លៃនៃផ្ទៃរាប/

៣- ស្តង់ដាដាតទុមសម្រាប់និយាមកាភូមិសាស្ត្រនិងស្តង់ដាដាតទុមសម្រាប់រយៈកម្ពស់នៃព្រះរាជាណាចក្រកម្ពុជា ត្រូវប្រើប្រាស់សម្រាប់គ្រប់ការងារវាស់វែង លើកលែងតែករណីដែលត្រូវបានអនុញ្ញាតដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រាប់តែគោលដៅវាស់វែងដីកោះដាច់តែងឯងឬក្នុងមូលហេតុពិសេស

៤- តម្លៃជាតួលេខនៃនិយាមកាភូមិសាស្ត្ររបស់ទីតាំងនិងស្ថានីយដាតទុមផ្ទៃរាបនិងស្តង់ដាដាតទុមរយៈកម្ពស់នៃព្រះរាជាណាចក្រកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

និយាមកាភូមិសាស្ត្រដែលចែងក្នុងចំណុច(១)ខាងលើ ត្រូវវាស់វែងនិងកំណត់ស្របទៅនឹងប្រព័ន្ធប្រឹថពីវិភាគសកល ដែលជាស្តង់ដានិយាមកាភូមិសាស្ត្រ និងដែលត្រូវបានវាស់វែងដោយការសន្មតថា ដែនដីគឺជាអេលីបសូអ៊ីដរង្វិលដែលមានតួលេខនៃទំហំនិងភាពសំប៉ែត ស្របទៅនឹងលក្ខខណ្ឌដូចខាងក្រោម៖

ក- ពាក់កណ្តាលអ័ក្សធំនិងភាពសំប៉ែតរបស់អេលីបសូអ៊ីតត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ខ- ផ្ចិតអេលីបសូអ៊ីដរង្វិលត្រូវស្ថិតនៅចំចំណុចកណ្តាលនៃទំនាញផែនដី

គ- ពាក់កណ្តាលអ័ក្សតូចរបស់អេលីបសូអ៊ីដរង្វិល ត្រូវស្ថិតនៅជាមួយអ័ក្សរង្វិលផែនដី។

**មាត្រា៩ .-**

ការវាស់វែងទូទៅឬការផលិតផែនទីជំនាញ ត្រូវប្រើប្រាស់ទិន្នន័យវាស់វែងគោលឬផែនទីគោលប្រសិនបើការវាស់វែងទូទៅឬការផលិតផែនទីជំនាញនេះ ធ្វើឡើងសម្រាប់គោលដៅសាធារណៈនិងសម្រាប់ការធ្វើអាជីវកម្ម។

## ជំពូកទី៤

## លក្ខណសម្បត្តិរបស់អ្នកវាស់វែងនិងការស្នើសុំវិញ្ញាបនបត្រវាស់វែង

**មាត្រា១០ .-**

រូបវន្តបុគ្គលដែលអាចស្នើសុំការទទួលស្គាល់សមត្ថភាពវាស់វែង ដើម្បីទទួលបានវិញ្ញាបនបត្រវាស់វែង ត្រូវមានលក្ខណសម្បត្តិ ដូចខាងក្រោម៖

-មានសញ្ញាបត្រ/វិញ្ញាបនបត្រជំនាញវាស់វែងថ្នាក់ឧត្តម ឬថ្នាក់មធ្យម ឬថ្នាក់បឋមនៃគ្រឹះស្ថានសិក្សាណាមួយដែលទទួលស្គាល់ដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច

-មានបទពិសោធការងារក្នុងមុខជំនាញវាស់វែងយ៉ាងតិច២(ពីរ)ឆ្នាំ។

**មាត្រា១១ .-**

រូបវន្តបុគ្គលដែលមានលក្ខណសម្បត្តិដូចមានចែងក្នុងមាត្រា១០នៃអនុក្រឹត្យនេះ ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រវាស់វែង នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

មន្ត្រីដែលកំពុងបម្រើការក្នុងស្ថាប័នរដ្ឋក៏អាចដាក់ពាក្យស្នើសុំវិញ្ញាបនបត្រវាស់វែង នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានដែរ។

**មាត្រា១២ .-**

វិញ្ញាបនបត្រវាស់វែងមានសុពលភាព៥(ប្រាំ)ឆ្នាំនិងអាចសុំបន្តបាន។

នីតិវិធីលម្អិតក្នុងការផ្តល់វិញ្ញាបនបត្រវាស់វែង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ការទទួលស្គាល់សមត្ថភាពវាស់វែងនិងការចេញវិញ្ញាបនបត្រវាស់វែងត្រូវមានការបង់ថ្លៃសេវា។ ថ្លៃសេវានេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូប-នីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៣ .-**

រូបវន្តបុគ្គលដែលពុំទាន់មានលក្ខណសម្បត្តិគ្រប់គ្រាន់ជាអ្នកវាស់វែង អាចបំពេញសកម្មភាពវាស់វែងបាន ដោយត្រូវស្ថិតនៅក្រោមការដឹកនាំនិងទទួលខុសត្រូវរបស់អ្នកវាស់វែងណាម្នាក់ដែលមានវិញ្ញាបនបត្រវាស់វែង។

## ជំពូកទី៥
## ការគ្រប់គ្រងក្រុមហ៊ុនវាស់វែង

**មាត្រា១៤ .-**

ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងមានសមត្ថកិច្ចរួចហើយ ដែលមានបំណងប្រកបអាជីវកម្មវាស់វែងនិង/ឬផលិតផែនទីនៅព្រះរាជាណាចក្រកម្ពុជា ត្រូវស្នើសុំអាជ្ញាបណ្ណវាស់វែងនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា១៥ .-**

ក្រុមហ៊ុនដែលអាចស្នើសុំអាជ្ញាបណ្ណវាស់វែងបាន ត្រូវមានលក្ខណសម្បត្តិអប្បបរមាដូចខាងក្រោម៖

១- ត្រូវមាននាយកបច្ចេកទេសមួយរូប ជាអ្នកវាស់វែងកម្រិតថ្នាក់ឧត្តមនិងមានបទពិសោធក្នុងមុខជំនាញវាស់វែងយ៉ាងតិច៣(បី)ឆ្នាំ

២- ត្រូវមានប្រាក់តម្កល់ធានាចំនួនពី១០ ០០០ ០០០(ដប់លាន)រៀលទៅ១០០ ០០០ ០០០(មួយរយលាន)រៀល ទៅតាមប្រភេទអាជីវកម្មវាស់វែងនិង/ឬផលិតផែនទី ដូចមានចែងក្នុងមាត្រា១៦នៃអនុក្រឹត្យនេះ។ ចំនួនប្រាក់តម្កល់ធានាដែលត្រូវបង់ដាក់ស្តែង ការគ្រប់គ្រងនិងការប្រើប្រាស់ប្រាក់នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៦ .-**

ប្រភេទអាជីវកម្មវាស់វែងនិង/ឬផលិតផែនទី មានជាអាទិ៍៖

-ការវាស់វែងបានលេខាក្នុងគោលដៅកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

- ការវាស់វែងឋានលេខាក្នុងគោលដៅកសាងសំណង់ស៊ីវិល
- ការផលិតទិន្នន័យវាស់វែងដោយប្រើឧបករណ៍ហ្វូតូក្រាមេទ្រីឬរីម៉ូតសិនស៊ីង
- ការផលិតផែនទីជំនាញមិនមែនជាឌីហ្ស៊ីថលឬជាឌីហ្ស៊ីថលសម្រាប់គោលដៅធ្វើអាជីវកម្ម
- សេវាបណ្តុះបណ្តាលលើការងារវាស់វែង
- សេវាកម្មពិគ្រោះយោបល់វាស់វែង
- សេវាកម្មគណនានិងបំលែងទិន្នន័យវាស់វែង
- សេវាកម្មចែកចាយទិន្នន័យវាស់វែងនិងផែនទី។

**មាត្រា១៧ .-**

បែបបទនិងនីតិវិធីនៃការស្នើសុំប្រកបអាជីវកម្មវាស់វែងនិង/ឬផលិតផែនទី និងការពិនិត្យសម្រេចលើការស្នើសុំអាជ្ញាបណ្ណវាស់វែង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។

**មាត្រា១៨ .-**

ក្នុងការស្នើសុំអាជ្ញាបណ្ណវាស់វែងនិងការចេញអាជ្ញាបណ្ណវាស់វែង ក្រុមហ៊ុនត្រូវបង់ថ្លៃសេវា។ ថ្លៃសេវានេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១៩ .-**

អាជ្ញាបណ្ណវាស់វែងមានសុពលភាពរយៈពេល៣(បី)ឆ្នាំគិតចាប់ពីថ្ងៃចេញអាជ្ញាបណ្ណវាស់វែង។

មុនពេលផុតកំណត់សុពលភាព៣០(សាមសិប)ថ្ងៃ ក្រុមហ៊ុនវាស់វែងត្រូវដាក់ពាក្យសុំបន្តអាជ្ញាបណ្ណវាស់វែងទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយភ្ជាប់មកជាមួយនូវអាជ្ញាបណ្ណវាស់វែងចាស់និងលិខិតបញ្ជាក់ការបង់ពន្ធដែលចេញដោយអគ្គនាយកដ្ឋានពន្ធដារ។

ក្រុមហ៊ុនវាស់វែងត្រូវផ្តល់របាយការណ៍អំពីសកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួន មកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅមុនថ្ងៃទី៣១ ខែមីនានៃឆ្នាំនីមួយៗ។

## ជំពូកទី៦

## សមាគមអ្នកវាស់វែង

**មាត្រា២០ .-**

អ្នកវាស់វែងនិងក្រុមហ៊ុនវាស់វែង មានសិទ្ធិបង្កើតសមាគមអ្នកវាស់វែងបានតាមច្បាប់ជាធរមាន។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវជួយគាំទ្រដល់ការរៀបចំបង្កើតសមាគមនេះ។

**មាត្រា២១ .-**

រចនាសម្ព័ន្ធគ្រប់គ្រងនិងរបៀបរបបធ្វើការងាររបស់សមាគម ត្រូវកំណត់ដោយលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់សមាគម។

**មាត្រា២២ .-**

សមាគមអ្នកវាស់វែងត្រូវរៀបចំក្រមសីលធម៌អ្នកវាស់វែង។ សមាគម[illegible] ក្រមសីលធម៌អ្នកវាស់វែង១ច្បាប់ទៅតម្កល់នៅក្រសួងរៀបចំដែនដី នគរូបនីយក[illegible]និងសំណង់។

## ជំពូកទី៧
## ទណ្ឌកម្ម

**មាត្រា២៣ .-**

ទណ្ឌកម្មនៅក្នុងអនុក្រឹត្យនេះ រួមមាន៖

- ការព្រមានជាលាយលក្ខណ៍អក្សរ
- ការព្យួរជាបណ្តោះអាសន្ននូវវិញ្ញាបនបត្ររាស់វែងឬអាជ្ញាបណ្ណរាស់វែង
- ការដកហូតនូវវិញ្ញាបនបត្ររាស់វែងឬអាជ្ញាបណ្ណរាស់វែង
- ការពិន័យអន្តរការណ៍។

ការដាក់ទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើ ជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២៤ .-**

អ្នករាស់វែងឬក្រុមហ៊ុនរាស់វែងណាដែលមិនបានបំពេញតាមស្តង់ដានិងបច្ចេកទេសកំណត់ដោយអនុក្រឹត្យនេះឬប្រកាសពាក់ព័ន្ធ ឬមានការធ្វេសប្រហែសដែលនាំឱ្យមានកំហុសធ្ងន់ធ្ងរក្នុងការងាររាស់វែងឬការងារផែនទី ត្រូវទទួលពិន័យអន្តរការណ៍ចំនួន១៥ ០០០ ០០០(ដប់ប្រាំលាន)រៀល។

បន្ថែមលើពិន័យអន្តរការណ៍ដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ អ្នករាស់វែង ឬក្រុមហ៊ុនរាស់វែងអាចទទួលរងបន្ថែមនូវទណ្ឌកម្មណាមួយឬច្រើន ដូចខាងក្រោម៖

- ព្រមានជាលាយលក្ខណ៍អក្សរ
- ព្យួរជាបណ្តោះអាសន្ននូវវិញ្ញាបនបត្ររាស់វែងឬអាជ្ញាបណ្ណរាស់វែង
- ដកហូតវិញ្ញាបនបត្ររាស់វែងឬអាជ្ញាបណ្ណរាស់វែង។

**មាត្រា២៥ .-**

បុគ្គលដែលបានធ្វើសកម្មភាពរាស់វែងនិង/ឬផលិតផែនទីដោយគ្មានវិញ្ញាបនបត្ររាស់វែងឬដោយគ្មានអាជ្ញាបណ្ណរាស់វែង ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៖

- ១០ ០០០ ០០០(ដប់លាន)រៀល សម្រាប់រូបវន្តបុគ្គលដែលធ្វើសកម្មភាពដោយគ្មានវិញ្ញាបនបត្ររាស់វែង
- ២០ ០០០ ០០០(ម្ភៃលាន)រៀល សម្រាប់ក្រុមហ៊ុនដែលធ្វើសកម្មភាពដោយគ្មានអាជ្ញាបណ្ណរាស់វែង។

បន្ថែមលើពិន័យអន្តរការណ៍ដូចចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបញ្ឈប់រាល់សកម្មភាពរាស់វែងនិង/ឬផលិតផែនទីរបស់បុគ្គលនោះជាបន្ទាន់។

ក្នុងករណីមិនគោរពតាមការបញ្ឈប់រាល់សកម្មភាពខាងលើ បុគ្គលនោះត្រូវទទួលរងពិន័យអន្តរការណ៍ទ្វេដង។

**មាត្រា២៦ .-**

បុគ្គលណាដែលបានប្រើប្រាស់វិញ្ញាបនបត្ររាស់វែងឬអាជ្ញាបណ្ណរាស់វែងក្លែងក្លាយ ក្នុងការធ្វើសកម្មភាពរាស់វែងនិង/ឬផលិតផែនទី ត្រូវពិន័យអន្តរការណ៍ជាប្រាក់ចំនួន៖

- ៥ ០០០ ០០០(ប្រាំលាន)រៀល សម្រាប់រូបវន្តបុគ្គលដែលធ្វើសកម្មភាពដោយប្រើប្រាស់វិញ្ញាបនបត្រវាស់វែងផុតសុពលភាព
- ១៥ ០០០ ០០០(ដប់ប្រាំលាន)រៀល សម្រាប់ក្រុមហ៊ុនដែលធ្វើសកម្មភាពដោយប្រើប្រាស់អាជ្ញាបណ្ណវាស់វែងផុតសុពលភាព

បន្ថែមលើពិន័យអន្តរការណ៍ដូចចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ក្រសួងរៀបចំដែនដី នគរូបនីកម្ម និងសំណង់ ត្រូវបញ្ឈប់រាល់សកម្មភាពវាស់វែងនិង/ឬផលិតផែនទីរបស់បុគ្គលនោះជាបន្ទាន់។

ក្នុងករណីមិនគោរពតាមការបញ្ឈប់រាល់សកម្មភាពខាងលើ បុគ្គលនោះត្រូវទទួលរងពិន័យអន្តរការណ៍ទ្វេដង។

**មាត្រា២៧ .-**

ស្ថាប័នមានសមត្ថកិច្ចត្រូវចងក្រងសំណុំរឿងបញ្ជូនទៅតុលាការ និងអាចសុំឱ្យរឹបអូសសម្ភារៈបរិក្ខារ ឧបករណ៍ផ្សេងៗទៀតដែលបានប្រើប្រាស់ធ្វើសកម្មភាព និងផលិតផលកើតចេញពីអំពើល្មើសដូចមានចែងក្នុងមាត្រា២៥និងមាត្រា២៦ ដោយអនុលោមតាមនីតិវិធីជាធរមាន ក្នុងករណីបុគ្គលដែលត្រូវទទួលទណ្ឌកម្មតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ មិនព្រមអនុវត្តតាមសេចក្តីសម្រេចរបស់ស្ថាប័នមានសមត្ថកិច្ច។

**មាត្រា២៨ .-**

នីតិវិធីនៃការពិន័យអន្តរការណ៍ ការបង់ប្រាក់ពិន័យ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យ និងការចាត់ចែងប្រាក់ចំណូលប្រមូលបានពីការពិន័យ ចំពោះអំពើល្មើសដូចមានចែងក្នុងជំពូកទី៧នេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឱ្យរលត់បណ្តឹងអាជ្ញា។

**មាត្រា២៩ .-**

មន្ត្រីមានសមត្ថកិច្ចណាដែលបដិសេធមិនព្រមពិនិត្យសំណុំលិខិតស្នើសុំវិញ្ញាបនបត្រវាស់វែងឬអាជ្ញាបណ្ណវាស់វែងដោយគ្មានមូលហេតុសមស្របត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលនិង/ឬទណ្ឌកម្មព្រហ្មទណ្ឌ ប្រសិនបើមាន។

មន្ត្រីមានសមត្ថកិច្ចណារួមគំនិតជាមួយបុគ្គលណាដែលធ្វើសកម្មភាពវាស់វែងនិង/ឬផលិតផែនទីដោយគ្មានវិញ្ញាបនបត្រវាស់វែង ឬដោយគ្មានអាជ្ញាបណ្ណវាស់វែង ឬប្រើប្រាស់វិញ្ញាបនបត្រវាស់វែងផុតសុពលភាព ឬប្រើប្រាស់អាជ្ញាបណ្ណវាស់វែងផុតសុពលភាព ដោយពុំរាយការណ៍ដល់អាជ្ញាធរមានសមត្ថកិច្ចដើម្បីមានវិធានការសមស្រប ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលនិង/ឬទណ្ឌកម្មព្រហ្មទណ្ឌ ប្រសិនបើមាន។

## ជំពូកទី៨
## អន្តរប្បញ្ញត្តិ

**មាត្រា៣០ .-**

ក្រុមហ៊ុនដែលបាននិងកំពុងប្រកបអាជីវកម្មវាស់វែងនិង/ឬផលិតផែនទីនៅព្រះរាជាណាចក្រកម្ពុជា

កម្ពុជាដោយគ្មានអាជ្ញាបណ្ណវាស់វែង ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណវាស់វែងពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងរយៈពេល១(មួយ)ឆ្នាំ ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន។

**មាត្រា៣១ .-**

រូបវន្តបុគ្គលដែលបាននិងកំពុងមានសកម្មភាពការងារវាស់វែងនៅព្រះរាជាណាចក្រកម្ពុជា ដោយគ្មានវិញ្ញាបនបត្រវាស់វែង ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រវាស់វែងពីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ក្នុងរយៈពេល១(មួយ)ឆ្នាំ ចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន។

## ជំពូកទី៩

## អវសានប្បញ្ញត្តិ

**មាត្រា៣២ .-**

អនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រងការផលិត និងការធ្វើអាជីវកម្មផែនទីនៃព្រះរាជាណាចក្រកម្ពុជានិងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹង អនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៣៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង មហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ។/៚

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០១ខែ កុម្ភៈ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## សទ្ទានុក្រម

### របស់អនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០១៦

### ស្តីពីការគ្រប់គ្រងលើការវាស់វែងនិងការផលិតផែនទីនិងលើអាជីវកម្មវាស់វែង និងការផលិតផែនទី

ការវាស់វែង (Surveying) សំដៅដល់រាល់ការវាស់វែងដីនិងតំបន់ឆ្នេរសមុទ្រ រួមទាំងការផលិតផែនទី និងការថតរូបសម្រាប់កិច្ចការវាស់វែងនិងផលិតផែនទី។

ផែនទី(Map) សំដៅដល់រូបភាពឬរូបគំនូរដែលជាទូទៅស្ថិតក្នុងប្លង់រាបនិងក្នុងមាត្រដ្ឋានកំណត់ តំណាងឱ្យវត្ថុឬបាតុភូតធម្មជាតិឬសិប្បនិម្មិតនៃផ្ទៃរបស់ផ្នែកណាមួយឬទាំងមូលរបស់ផែនដីឬភពផ្សេងទៀត។

ការវាស់វែងគោល(Basic surveying) សំដៅដល់ការវាស់វែងដែលជាគ្រឹះនៃការងារវាស់វែងទាំងអស់ រួមមានការវាស់វែងប្រឹថពីវិភាគ(ប្លង់រាបនិងរយៈកម្ពស់) ការវាស់វែងសុរិយោដី ការវាស់វែងព្រំប្រទល់រដ្ឋបាលនិងព្រំប្រទល់ប្រទេស ការផលិតផែនទីគោល ការថតរូបពីលើអាកាស និងរូបភាពដទៃទៀតក្នុងគោលដៅផលិតទិន្នន័យភូមិសាស្ត្រ។

ការវាស់វែងទូទៅ (General surveying) សំដៅដល់ការវាស់វែងក្រៅពីការវាស់វែងគោល ដែលអាចធ្វើឡើងដោយស្ថាប័នរដ្ឋ អង្គភាព ឬបុគ្គលឯទៀត ដូចជាការវាស់វែងផ្នែកសំណង់ស៊ីវិល ការវាស់វែងព្រំដែលពុំទាមទារភាពជាក់លាក់ខ្ពស់ ការផលិតផែនទីតាមជំនាញ។

អ្នកវាស់វែង (Surveyor) សំដៅដល់រូបវន្តបុគ្គលដែលបានចុះបញ្ជីទទួលស្គាល់សមត្ថភាពវាស់វែងនិងដែលទទួលបានវិញ្ញាបនបត្រវាស់វែងចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ក្រុមហ៊ុនវាស់វែង (Surveying company) សំដៅដល់ក្រុមហ៊ុនដែលបានចុះបញ្ជីក្រោមច្បាប់កម្ពុជានិងដែលបានទទួលអាជ្ញាបណ្ណវាស់វែងនៅព្រះរាជាណាចក្រកម្ពុជា។

អាជ្ញាបណ្ណវាស់វែង (Surveying license) សំដៅដល់វិញ្ញាបនបត្រប្រកបអាជីវកម្មវាស់វែងនិង/ឬផលិតផែនទី ដែលចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់តាមការស្នើសុំរបស់ក្រុមហ៊ុន។

ទិន្នន័យវាស់វែង(Surveying data) សំដៅដល់ទិន្នន័យក្នុងទម្រង់ជាការសរសេរ ឬរូបភាព ឬជាឌីហ្ស៊ីថលដែលបានមកពីការអនុវត្តកិច្ចការវាស់វែង រហូតសម្រេចបានជាលទ្ធផលវាស់វែង។ ទិន្នន័យនេះមានពីរប្រភេទ គឺទិន្នន័យដើម ជាទិន្នន័យដែលពុំទាន់កែច្នៃ និងទិន្នន័យសម្រេចជាទិន្នន័យដែលបានគណនាឬរៀបចំឡើងចេញពីទិន្នន័យដើម។

ការផលិតផែនទី(Mapping) សំដៅដល់កិច្ចការផលិតផែនទីក្នុងទម្រង់ជាការបោះពុម្ព ឬជាឌីហ្ស៊ីថល ដោយផ្អែកលើទិន្នន័យវាស់វែងជាផ្លូវការ។

ផែនទីគោល(Basic map)សំដៅដល់ផែនទីដែលផលិតចេញពីទិន្នន័យជាលទ្ធផលនៃការវាស់វែងគោល។

ផែនទីជំនាញ (Thematic map) សំដៅដល់ផែនទីដែលផលិតចេញពីទិន្នន័យជាលទ្ធផលនៃការវាស់វែងទូទៅឬដែលប្រើផែនទីគោលជាមូលដ្ឋាន។

ឧបករណ៍ហ្វូតូក្រាមេទ្រី (Photogrametric instrument) សំដៅដល់ឧបករណ៍សម្រាប់កំណត់ទំហំ រាង និងទីតាំងវត្ថុ តាមរូបថតពីលំហអាកាស ឬនៅលើដីដែលទិន្នន័យទទួលបាន ត្រូវប្រើសម្រាប់កិច្ចការផលិតផែនទី។

រីម៉ូតសិនស៊ីង (Remote sensing) សំដៅដល់បច្ចេកទេសដើម្បីទទួលបានទិន្នន័យភូមិសាស្ត្រពីចម្ងាយ(ឧទាហរណ៍ ពីយន្តហោះឬពីផ្កាយរណប)។

និយាមកា (Coordinate) សំដៅដល់ចំនួនតួលេខជាមុំឬជាបន្ទាត់ ដែលកំណត់អំពីទីតាំងរបស់ចំណុចនីមួយៗនៅក្នុងបណ្តាញឬប្រព័ន្ធកំណត់ណាមួយ។

និយាមកាភូមិសាស្ត្រ (Geographic coordinate) សំដៅដល់ចំនួនតួលេខនៃរយៈទទឹងនិងរយៈបណ្តោយ ដែលកំណត់បាននូវទីតាំងចំណុចនីមួយៗនៅលើផែនដី ដោយផ្អែកទៅលើអេលីបសូអ៊ីដយោង។

និយាមកាចតុរង្គ (Grid coordinate) សំដៅដល់និយាមកាស្ថិតក្នុងប្រព័ន្ធមួយ ដែលក្នុងនោះ តួលេខនិងតួអក្សរត្រូវបានប្រើសម្រាប់កំណត់ទីតាំងនៃចំណុចមួយនៅលើផែនទីដែលមានបែងក្រឡាចតុរង្គ។

និយាមកាមុំ (Polar coordinate) សំដៅដល់និយាមកាដែលត្រូវបានប្លែងចេញពីការវាស់វែងចម្ងាយនិងមុំពីចំណុចថេរមួយ។

ដាតទុម (Datum) សំដៅដល់សំណុំចំណុចយោងស្ថិតលើផ្ទៃផែនដី ដែលចេញពីនោះ ទីតាំងនីមួយៗត្រូវបានវាស់វែង កំណត់ឡើង និងត្រូវបានភ្ជាប់ជាមួយគំរូម៉ូដែលនៃរូបរាងរបស់ផែនដី(គឺអេលីបសូអ៊ីដយោង) សម្រាប់ប្រើក្នុងការកំណត់នូវប្រព័ន្ធនិយាមកាភូមិសាស្ត្រនិងរយៈកម្ពស់។ ដាតទុមមានពីរប្រភេទគឺ (១) ដាតទុមផ្ទៃរាប ត្រូវបានប្រើសម្រាប់រៀបរាប់ពីចំណុចមួយនៅលើផ្ទៃផែនដី ជារយៈទទឹងនិងរយៈបណ្តោយ ឬជានិយាមកាផ្សេងទៀត។ និង(២) ដាតទុមកម្ពស់ ប្រើសម្រាប់ការវាស់វែងរយៈកម្ពស់ ឬជម្រៅ។

អេលីបសូអ៊ីដ (Ellipsoid) ជាទូទៅហៅថា អេលីបសូអ៊ីដយោង សំដៅដល់ផ្ទៃគណិតដែលស្ទើរតែដូចទៅនឹងផ្ទៃផែនដី និងត្រូវកំណត់ឡើងសម្រាប់បម្រើឱ្យការងារវាស់វែងនិងផលិតផែនទី។

ហានលេខា (Topography) សំដៅដល់ការកត់ត្រាដោយលំអិតនិងជាក់លាក់អំពីទីភូមិសាស្ត្រ